# រឿង
# ប៉ាវប៉ាវតូច
# MY LITTLE PAOPAO



សាយ រស្មី
ឱម វិរិយា

ប៉ាវប៉ាវតូច **(My Little PaoPao)**

**Written by** Say Reaksmey
**Artwork by** Om Virya

**Co-Editors** Sai Yee Tip,
Prak Monirath,
Uoeung Bonsovathary

**Art Editor** San Somanear

**Reviewed by** Khmer Youth Association (KYA),
Love is Diversity

Publisher Khmer Youth Association (KYA)
No. 32D, St. 562, Phnom Penh12151, Cambodia

Copyright © 2024 by Khmer Youth Association (KYA)

All rights reserved.
Without limiting the rights under the copyright reserved above, no part of this publication may be reproduced, stored in or introduced into a retrieval system, or transmitted, in any form, or by any means (electronic, mechanical, photocopying, recording, or otherwise), without the prior written permission of the copyright owner.
Published in Phnom Penh, Cambodia.

A catalog record for this book is available from
the National Library of Cambodia
ISBN: 978-9924-9966-2-0

Disclaimer: This storybook is made possible by the generous support of the American people through the United States Agency for International Development (USAID)-funded Civil Society Support (CSS) Activity implemented by Family Health International (FHI360). The contents are the responsibility of Khmer Youth Association and do not necessarily reflect the views of USAID or the United States Government.

# រឿង

# ប៉ាវប៉ាវតូច

# MY LITTLE PAOPAO



កាលពីព្រេងនាយមានភពមួយ
លាក់កំបាំងឆ្ងាយពីភពដទៃទៀតក្នុង
ចក្រវាលដ៏អាថ៌កំបាំងធំមហិមានេះ

ហើយភពនេះត្រូវបានគេឱ្យ
ឈ្មោះថា «**ភពនៃសន្តិភាព**»
ប៉ុន្តែបើគ្រប់យ៉ាងនៅទីនេះ
មានតែពណ៌ផ្កាឈូក និង
ពណ៌ខៀវអ៊ីចឹង

តើគួរតែហៅថាភពនៃសន្តិភាព
ឬជាភពពីរពណ៌ទៅ?

កាលពីដើមឡើយ ប្រជាជនទាំងអស់បែងចែកចេញជាពីរភេទប៉ុណ្ណោះ ហើយភេទត្រូវបានកំណត់សម្គាល់តាមរយៈពណ៌រាងកាយរបស់ពួកគេដោយភេទស្រីមានរាងកាយពណ៌ផ្កាឈូក និងភេទប្រុសមានរាងកាយពណ៌ខៀវ ហើយគ្រប់យ៉ាងបន្តបែបនេះរហូត...



ដល់ទារកម្នាក់ចាប់កំណើតមកជាមួយរាងកាយដែលមានពណ៌ចម្រុះប្រៀបបី ដូចជាឥន្ទធនូ ហើយគេក្លាយជាភាវៈចម្លែកដែលគ្មានភេទច្បាស់លាស់។




បើទោះបីប៉ាវៗត្រូវរងការរើសអើងម៉ាក់ងាយមិនទទួលស្គាល់ ឬឱ្យតម្លៃពីភាវៈខាងក្រៅតែគេមានគ្រួសារមួយ ដែលកក់ក្ដៅហើយចាំគាំទ្រគេគ្រប់ពេលវេលា គ្រប់កាលៈទេសៈតាំងពីតូចក្រូចឆ្មារហូតដល់ប៉ាវៗឈានចូលវ័យនៅកម្រិតថ្នាក់វិទ្យាល័យ។




ឧទ្យានវេទមន្ត (រាត្រីកាល)
គ្រប់យ៉ាងចំពោះមុខហាក់ដូចជារឿងព្រេងនិទាន អំពិលអំពែករាប់រយហោះបំភ្លឺ ផ្លូវនាំប៉ាវៗទៅកាន់ក្លោងទ្វាឧទ្យានមួយ
ប៉ាវៗ បោះជំហាន ឆ្លងកាត់ក្លោងទ្វាហើយ រំពេចនោះវេទមន្តក៏ កើតមានឡើង។
ផ្កាក្នុងឧទ្យានទាំងអស់បញ្ចេញពន្លឺភ្លឺចិញ្ចាច។ អំពិលអំពែករាប់ពាន់ហោះចេញពីគ្រប់ទិសទី មកហោះព័ទ្ធជុំវិញប៉ាវៗ

វេទមន្តដ៏អស្ចារ្យនិមិត្តឈុតរ៉ូបដ៏ប្រណិតប្រែពណ៌រាងកាយរបស់ប៉ាវៗទៅជាពណ៌ផ្កាឈូក ខណៈនេះប៉ាវៗមើលទៅដូចជាទេពអប្សរអីចឹង



ប៉ាវៗ ញញឹមឡើងដោយសេចក្តីពេញចិត្ត ហើយឈានទៅឈរមុខកញ្ចក់ដែលមានរាងជាពងក្រពើស្រាក់ជាប់ជាមួយវល្លិ៍ឈើស្ថិតនៅមិនប៉ុន្មានជំហានពីប៉ាវៗ


ប៉ាវៗឈរញញឹមមើលខ្លួនឯងនៅមុខកញ្ចក់
អូ...កូននរណាគេទៅនៀក? ស្អាតម្លឹងៗ លោកអើយ
ពេលនេះខ្ញុំមានអារម្មណ៍ថា ខ្ញុំស្អាតដូចជាព្រះនាងក្នុង រឿងនិទានអញ្ចឹង
សមគ្មានទាស់តែម្តងហើយ ខ្ញុំស្រលាញ់ឈុតនេះណាស់


ប៉ាវៗងាកទៅតាមសំឡេង ឃើញថាជាវត្តមានរបស់ ព្រះបុត្រាមួយព្រះអង្គជិះនៅ លើខ្នងសេះស
ព្រះបុត្រាសម្លឹងប៉ាវៗមិន ដកភ្នែក សម្រូតចុះពីលើ ខ្នងសេះ
ប៉ាវៗឮពាក្យសរសើររបស់ព្រះបុត្រា ហើយ ថ្ពាល់គេឡើងក្រហមអោនមុខ ចុះគេចក្រសែភ្នែក
តើជាមនុស្ស ឬជាទេពអប្សរ? ម្តេចក៏ស្រស់ផូរផង់យ៉ាងនេះ? បានជួបគ្នាអាចរាប់ថាពួកយើង មាននិស្ស័យ។




ព្រះចន្ទមូលក្រឡង់ ហ្វូងអំពិលអំពែកហោះកាត់ពាសពេញមេឃ ផ្កាយជះពន្លឺចិញ្ចាច និងឆ្លៀតបញ្ចេញសូរ្យសៀងតន្ត្រីយ៉ាងពិរោះរណ្ដំ។ ព្រះបុត្រា និងប៉ាវៗរាំនៅកណ្ដាលឧទ្យានវេទមន្តយ៉ាងអន្លង់អន្លោចស្នាមញញឹមផ្អែមល្ហែមប្រាកដឡើង កែវភ្នែកសម្លឹងគ្នាទៅវិញទៅមកឥតព្រិចមួយវិនាទីសោះឡើយ។


ប៉ុន្តែពេលវេលាល្អហាក់មកដល់
ពេលកំណត់ សំឡេងតន្ត្រីស្ងាត់ទៅ
MIDNIGHT
ផ្កាដែលចាំងជះពន្លឺក៏ប្រែជាស្រអាប់ងងឹតម្ដងមួយៗ
អំពិលអំពែកហោះចាកចេញពីឧទ្យានទៅបាត់អស់
ឈុតដែលនិមិត្តឡើងដោយវេទមន្តរបស់ប៉ាវៗក៏របេះជ្រុះផ្កាចេញម្ដងមួយៗ
ហើយពណ៌រាងកាយរបស់ប៉ាវៗចុងក្រោយក៏ប្រែមកសភាពដើមវិញ
ប៉ាវៗ បានត្រឹមឈរស្រឡាំងកាំងមើលគ្រប់យ៉ាងរលាយផេះផង់ទៅនៅចំពោះមុខ
ព្រះបុត្រា។ ប៉ាវៗ អោនមុខចុះជាថ្មីដោយក្ដីអៀនខ្មាស់
ព្រះបុត្រាឃើញពណ៌រាងកាយពិតរបស់ខ្ញុំហើយប្រាកដជាមិនចូលចិត្តខ្ញុំទៀតទេ ខ្ញុំជាភាវៈចម្លែកដែលគ្មានភេទច្បាស់លាស់

ប៉ាវៗ ផ្លោយបង្ហូរទឹកភ្នែកចេញមក។
ព្រះបុត្រា ឈានចង់ចូលទៅក្បែរប៉ាវៗ តែប៉ាវៗក៏រត់ចាកចេញទៅតែម្តង។






ទោះជាយ៉ាងណា ប៉ាវៗនៅតែបន្តរត់ចេញទៅ
ដោយមិនងាកក្រោយ។




បន្ទប់គេងរបស់ ប៉ាវៗ
ប៉ាវៗគេងយំអណ្ដឹតអណ្ដកសើម ជោកខ្នើយ។ ប៉ាវៗងើបអង្គុយហើយ យកដៃជូតទឹកភ្នែក
យល់សប្តិសោះ ភ័យលួសព្រលឹងអស់ តែយល់សប្តិអី ក៏កំសត់សម្បើមម្ល៉េះ? រឿងដែលថាខ្ញុំ មានពណ៌រាងកាយខុស គេជាភេទមិន ច្បាស់លាស់នេះ តាមលងបន្លាចខ្ញុំគ្រប់ វិនាទី កាន់តែព្យាយាមលាក់គឺកាន់តែ តាមលងបន្លាច។
បន្ទប់ទឹករបស់ ប៉ាវៗ
ប៉ាវៗ ឈរកាន់កំប៉ុងទឹកថ្នាំពណ៌ខៀវក្លូរឧបករណ៍ លាបពណ៌។ ប៉ាវៗ មានទឹកមុខស្រងូតស្រងាត់
ខ្ញុំសម្រេចចិត្តលាបពណ៌បិទបាំងរាងកាយដែលតំណាងឲ្យភេទមិន ច្បាស់លាស់របស់ខ្ញុំនេះ តាំងពីខ្ញុំបញ្ចប់កម្រិតថ្នាក់បឋមសិក្សាមកម្ល៉េះ មូលហេតុគឺដោយសារតែ


តើគេមានភេទអ្វីទៅ?
ពួកឯងឃើញទេ គេមានពណ៌រាងកាយចម្លែកណាស់
ក្មេងចម្លែកមានភេទមិនច្បាស់លាស់
អតីតកាលថ្ងៃចូលរៀនដំបូង
បើរាងកាយឯងមានពណ៌ចម្រុះបែបនេះ តើឯងភេទអ្វីទៅ?
ប៉ាវៗ គាំងស្លេញគេបែកញើសជោក ឆ្លើយមិនចេញ


កូនៗ ថ្ងៃនេះលោកគ្រូនឹងរៀបចំចែកក្រុមជាប្រាំក្រុម ដើម្បីឱ្យកូនៗបោសសម្អាតថ្នាក់រៀនរបស់ពួកយើងណា
កូនៗណាខ្លះចង់រៀននៅក្នុងថ្នាក់រៀនដែលស្អាតហើយមានអនាម័យ?
ឆ្លាតណាស់កូនៗ តស់ ឥឡូវចាប់ផ្ដើមចាប់ក្រុម ដោយមួយក្រុមមានសមាជិកបី ឬ បួននាក់
បាទ/ចាស
សួស្ដី... ខ្ញុំសូមចូលក្រុមជាមួយផងបានទេ?
មែនហើយ ! ខ្ញុំឮគេនិយាយថាឯង ពូកែរំអួយច្រើនហើយទន់ជ្រាយទៀតផង
អត់ទេ... ឯងជាក្មេងចម្លែកគ្មានសម្បុរភេទច្បាស់លាស់
ប៉ាវៗ បានត្រឹមតែតូចចិត្តអោនមុខចុះ រកចង់យំ
ពួកយើងមិនចង់បានឯងចូលមកក្រុមពួកយើងទេ។


ត្រឡប់មកបច្ចុប្បន្ន
ប៉ាវៗ យកទឹកថ្នាំពណ៌ខៀវលាបសព្វរាងកាយពណ៌ចម្រុះរបស់គេ
ប៉ាវៗ រត់កាត់សមាជិកគ្រួសារដែលកំពុងរៀបចំហូបបាយពេលព្រឹក
កូនអត់ញ៉ាំបាយព្រឹកទេថ្ងៃហ្នឹង?
កូនអត់ញ៉ាំទេម៉ាក់
ដោយសារតែកូនយឺតម៉ោងចូលរៀនហើយ
អីចឹង...ប៉ាវៗយកបាយស្រូបសាច់ជ្រូកពងមាន់ខ្ចប់ទៅញ៉ាំនៅសាលាទៅកូន។ ម៉េចអីចឹងកូនចិត្តចិត្តញ៉ាំវាត្រូវទេ?
បាទម៉ាក់ ប៉ុន្តែខ្ញុំអត់ចង់ញ៉ាំទេ
កូនយឺតម៉ោងចូលរៀនមែនណា...



មុខក្លោងទ្វារវិទ្យាល័យ
វេទមន្តដំឡូងខៀវ
រវល់តែក្រៀមក្រំគិតរឿង
ទាំងនោះ ថ្ងៃនេះខ្ញុំមករៀនយឺត
១៥ នាទីទៀតហើយ ប្រាកដជាត្រូវ
ទទួលពិន័យទៀតមិនខាន ខ្ញុំទើបតែ
បោសសម្អាតសាលវិចិត្រសិល្បៈ
ហើយទេ កាលពីអាទិត្យមុន
ចំជាហេងមែន ថ្ងៃនេះ
អ្នកគ្រូមកបង្រៀនយឺតដែរ
ម៉េចក៏កូនមក
រៀនយឺតទៀត
ហើយប៉ាវៗ?
គឺ...គឺៗ...
យប់មិញខ្ញុំយល់សប្តិ
ឃើញអ្នកគ្រូស្អាតអើយ
សែនស្អាតដូចជាទេពធីតា
អីចឹង ដោយសារតែ
បែបនេះហើយទើបខ្ញុំភ្ញាក់
មករៀនយឺត
ពិតមែនឬប៉ាវៗ ពិតជា
យល់សប្តិឃើញអ្នកគ្រូ
បែបនេះមែន?
បាន ថ្ងៃនេះឱ្យកូន
រួចខ្លួនម្តងចុះ ចូលតុ
អង្គុយលឿនៗទៅ


កូនៗ អ្នកគ្រូទើបមកប្រជុំនៅទីចាត់ការអម្បាញ់មិញនេះ ហើយមានដំណឹងមួយចង់ប្រកាសប្រាប់កូនៗ
នៅចុងខែនេះវិទ្យាល័យពួកយើងមានការប្រកួតដ៏ធំមួយជាមួយ វិទ្យាល័យល្បីឈ្មោះមកពីទីក្រុងដោយវិញ្ញាសារប្រកួតមានដូចជា កីឡាជីជីតស៊ូ កីឡាបាល់ទាត់ កីឡាហែលទឹក
ហើយចុងក្រោយគឺការប្រកួតទេពកោសល្យវេទមន្តបង្កើតភាពច្នៃប្រឌិតថ្មីបំផុត។ ការប្រកួតនេះដែរគឺពិតជាសំខាន់សម្រាប់វិទ្យាល័យយើង ដោយហេតុថាវិទ្យាល័យណាដណ្តើមបានជ័យលាភីឯកនោះ គឺទទួលបានកញ្ចប់ប្រាក់ឧបត្ថម្ភដ៏ធំពីក្រសួងអភិវឌ្ឍន៍យុវជន
វាល្មមគ្រប់គ្រាន់សម្រាប់វិទ្យាល័យពួកយើងយកមកចំណាយជួសជុលអគារសិក្សាចាស់ៗក៏ដូចជាសាងសង់ថ្មីបន្ថែមសម្រាប់កូនៗសិស្សានុសិស្សទាំងអស់ រឹតតែសំខាន់ទៀតនោះ សិស្សដែលត្រូវបានផ្តល់ឱកាស លើកទឹកចិត្តឱ្យចូលរួមប្រកួតតំណាងវិទ្យាល័យវេទមន្តដំឡូងខៀវជាសិស្សថ្នាក់ពួកយើងនេះឯង
ដូច្នេះហើយកូនៗអាចមកចុះឈ្មោះចូលប្រកួតវិញ្ញាសារណាមួយដែលកូនៗគិតថាសាកសមជាមួយកូនៗនៅតុអ្នកគ្រូបានណា


ស្រមៃដល់ពេលពេលទទួល
ពានជ័យលាភី
មួយសន្ទុះក្រោយមកក៏ភ្ញាក់មកវិញ ហើយគ្រវីក្បាលញាប់ឆ្មេរ ប្រែទឹកមុខមក
ស្រងូតស្រងាត់វិញ
គិតដល់អតីតកាល
ចុះបើខណៈពេលប្រកួតខ្ញុំហូររលុប
ទឹកថ្នាំពណ៌ខៀវចេញពណ៌រាងកាយ
ពិតប្រាកដរបស់ខ្ញុំគិតយ៉ាងម៉េចទៅ?
ការប្រកួតទាំងនេះមិនសាកសមនឹងខ្ញុំ
នោះទេ។ ខ្ញុំមិនគួរចូលរួមទេ។


ខ្ញុំមិនអាចហែលទឹកសមុទ្រហើយត្រូវដូរមកហែលទឹកពាងនៅផ្ទះ
មិនអាចគេងហាលថ្ងៃបាន
សូម្បីតែឈរចាំមីឆាក៏ក្លាយជាផលវិបាកមួយរបស់ខ្ញុំដែរ
ព្រោះត្រូវកាន់កង្ហារទៅតាម នោះអី បើមិនដូច្នេះទេឈរក្បែរ ខ្ទះឆាក្ដៅហូរញើសរលុបទឹក ថ្នាំមិនខាន ទោះជាយ៉ាងណា លាក់បាំងបែបនេះក៏ប្រសើរជាង ត្រូវគេចំអន់ និងលេងសើចដែរ ប៉ាវៗមានទឹកមុខក្រៀមក្រំជា ពន់ពេក។



មនុស្សចូលរួមច្រើនអធិកអធម កៅអីអង្គុយបែងចែកជាពីរក្រុម ដោយសិស្សដែលគាំទ្រ
វិទ្យាល័យវេទមន្តដំឡូងខៀវអង្គុយមួយចំហៀងខាងឆ្វេង ហើយក្រុមសិស្សដែលមក
គាំទ្រវិទ្យាល័យវេទមន្តផ្កាឈូកក្រពុំអង្គុយមួយចំហៀងខាងស្តាំ


លោកនាយកវិទ្យាល័យ
វេទមន្តដំឡូងខៀវ
ក្រសួង
អភិវឌ្ឍន៍យុវជន
លោកស្រីនាយិកាវិទ្យាល័យ
វេទមន្តផ្កាឈូកក្រពុំ
ក្រុមការងារមកពីប៉ុស្ត៍ទូរទស្សន៍ កំពុងផ្តិតយកសកម្មភាពក្នុង ការប្រកួតទាំងមូលក៏ដូចជាធ្វើកិច្ច សម្ភាសន៍ផ្សេងៗផងដែរ
ប៉ាវៗ អង្គុយកៅអីមួយដាច់ពីគេនៅខាងលើបង្អស់។ នៅជុំវិញប៉ាវៗមានកង្ហាររហូត ដល់ប្អូនឯណោះ គឺដាក់ពីលើពីក្រោមខាងឆ្វេងខាងស្តាំគ្រប់ទិសតែម្តង។ គេមាន កាន់ប៉េងប៉ោងបញ្ជាក់ការគាំទ្រ។


ការប្រកួតចាប់ផ្ដើមពី
ការប្រកួតកីឡាជីជីតស៊ូ
បន្តមកទៀតគឺការប្រកួត
កីឡាបាល់ទាត់
បន្តមកការប្រកួតទី៣ គឺ
ការប្រកួតកីឡាបាល់ទះ
ដោយលទ្ធផលគឺវិទ្យាល័យ
វេទមន្តដំឡូងខៀវជាអ្នកឈ្នះ
TIE
05 - 05
ដែលលទ្ធផលគឺ ៣-៣ ក្រោយ
ប្រកួតអស់រយៈពេល ៩៦ នាទី
ដោយលទ្ធផលគឺក្រុមវិទ្យាល័យ
ផ្កាឈូកក្រពុំបានយកឈ្នះ
00:00
03
03




ដោយសិស្សមួយក្រុម គឺកំណត់មានសមាជិកចំនួនប្រាំនាក់។ ពួកគេចាប់ផ្ដើមធ្វើការតម្រង់ជួរត្រៀមដើរចូលទៅកាន់សួនច្បារទីតាំងប្រកួត។ យើងឃើញជួរក្រុមសិស្សវិទ្យាល័យវេទមន្តផ្កាឈូកក្រពុំមានសមាជិកប្រាំនាក់គ្រប់ទៅតាមការកំណត់ហើយ ក៏ដើរចូលទៅក្នុងសួនច្បារដែលជាទីតាំងប្រកួតរបស់ពួកគេមុនបាត់។


រីឯក្រុមសិស្សវេទមន្តជំទ្បូងខៀវវិញ
គឺមានសមាជិកតែបួននាក់ប៉ុណ្ណោះ
ហេតុអីក៏មានតែបួននាក់ អញ្ចឹង ឯណាកូនដុកដែន?
ដុកដែនញ៉ាំចំណីខុស ឈឺពោះកាលពីព្រឹកមិញហើយ ម៉ាក់របស់គេបានមកយកគេ ទៅផ្ទះបាត់ហើយ អ្នកគ្រូ
អ្ហា !!!!
ម៉េចក៏អ្នកមិនដឹង?
គិតយ៉ាងម៉េច ទៅពួកយើង ខ្វះសមាជិក ម្នាក់ហើយ ពេលនេះ
ខណៈអ្នកគ្រូកំពុងស្លន់ស្លោ យើង បែរទៅមើល ប៉ាវៗឃើញថាកំពុង អង្គុយបិទភ្នែកស្រម៉ុក ខុលៗ
គេហាក់លង់លក់ក្នុងដំណេកបាត់ទៅហើយប៉ាវៗ វេខ្លួនចុះឡើងៗ ចុងក្រោយក៏ស្រាប់តែរមៀលធ្លាក់
ដូចជាបាល់ពីកៅអីអង្គុយរបស់គេ មកធ្លាក់ប៉ុក ក្បែរកន្លែងអ្នកគ្រូឈរ។


លូកដៃឱ្យប៉ាវៗតោងងើបឈរឡើងដោយលេចចេញស្នាមញញឹមហាក់បង្កប់អ្វី
ម្យ៉ាងនៅលើផ្ទៃមុខអក្សរ V របស់គាត់។
ស្វាគមន៍មកក្លាយជា
សមាជិកក្រុមប្រកួត
ប៉ាវៗ
ខណៈនៅក្រាបនៅលើ
ដីនៅឡើយគ្រាន់តែឮ
បែបនេះក៏ប្តូរទឹកមុខមក
ស្លន់មួយរំពេចភ្លេចអស់
ការឈឺចាប់រមៀលពី
កៅអីអង្គុយខាងលើមក
ដល់ក្រោមអម្បាញ់មិញ
ត្រៀមៗ គាត់និយាយ
ម្តងម្នាក់ទៅកាន់ក្រុម
ទាំងពីរ
ពេលវេលាដែល
ទន្ទឹងរង់ចាំបាន
មកដល់
ការប្រកួត
ចាប់ផ្តើម !


សិស្សទាំងពីរក្រុមចាប់ផ្ដើមញាប់ដៃញាប់ជើងរត់ចុះរត់ឡើងនិមិត្តនេះនោះឡើងជាច្រើន
លម្អសួនច្បាររបស់ពួកគេ។ ប៉ាវៗ នៅឈរស្ងៀមដោយសារមិនដឹងគួរធ្វើអ្វី។
សិស្សប្រុសពីរនាក់ព្យាយាមលើករូបចម្លាក់រូបអណ្ដើកមួយ
ដែលពួកគេនិមិត្តចេញមក ប៉ុន្តែវាមានទម្ងន់ធ្ងន់ជាខ្លាំង។
ប៉ាវៗ ឯងនៅឈរធ្វើអី? ពួកយើងកំពុងប្រកួតណា
មែនហើយ លឿនឡើងមកជួយ លើកពួកយើងមកបើឯងគ្មានគំនិត ឬទេពកោសល្យវេទមន្តអ្វីពិសេស
រត់ចូលទៅជួយលើកពួកគេ ហើយចុងក្រោយពួកគេ ក៏អាចផ្លាស់ទីរូបចម្លាក់ អណ្ដើកនោះទៅដាក់ទីតាំង ដែលពួកគេចង់បាន
សិស្សៗ ហាក់សហការបានយ៉ាងល្អដោយពួកគេផ្លាស់វេនគ្នានិមិត្តរបស់របរផ្សេងៗ
និងបញ្ជូនវាទៅតុបតែងឱ្យបានស្រស់ស្អាតត្រឹមត្រូវ លើកលែងតែប៉ាវៗមួយទេ ដែល
គេមិនហ៊ានបញ្ចេញវេទមន្តរបស់គេសោះឡើយ គឺបានត្រឹមតែជួយបញ្ជូនប៉ុណ្ណោះ។
ការពិតទៅខ្ញុំមិនមែនគ្មានទេពកោសល្យ វេទមន្ត ឬ គំនិតច្នៃប្រឌិតអ្វីសោះតែ ម្ដងនោះទេ ខ្ញុំមានគំនិតជាច្រើនប៉ុន្តែ បើសិនជាខ្ញុំប្រើប្រាស់វេទមន្តរបស់ខ្ញុំ ពណ៌រាងកាយធម្មជាតិរបស់ខ្ញុំនឹងបង្ហាញ ឡើងចំពោះមុខគ្រប់គ្នានៅទីនេះ


ការពិតទៅខ្ញុំមិនមែនគ្មានទេពកោសល្យ វេទមន្ត ឬ គំនិតច្នៃប្រឌិតអ្វីសោះតែម្តងនោះ ទេ ខ្ញុំមានគំនិតជាច្រើន
ខ្ញុំចង់តែរត់គេចពី ការប្រកួតមួយនេះទេ ប៉ាម៉ាក់ជួយកូនផង
ប៉ុន្តែបើសិនជាខ្ញុំប្រើប្រាស់វេទមន្តរបស់ខ្ញុំ ពណ៌រាងកាយធម្មជាតិរបស់ខ្ញុំនឹងបង្ហាញ ឡើងចំពោះមុខគ្រប់គ្នានៅទីនេះ
ខ្ញុំភ័យណាស់ ភ័យថាទឹកថ្នាំ ពណ៌ខៀវដែលលាបរាងកាយ របស់ខ្ញុំហូររលុបហើយពណ៌សម្បុរ ចម្រុះពណ៌ដែលបញ្ជាក់ពីភេទមិន ច្បាស់របស់ខ្ញុំត្រូវលេចឡើង
យើងឃើញប៉ាវៗ តែងតែរត់ទៅពួនលួចអូស ទឹកថ្នាំថែមជារឿយៗ។
ការប្រកួត គឺពិតជាអស្ចារ្យ មែនទែនបាទ មើលទៅក្រុម នីមួយៗកំពុងតែញាប់ដៃ ញាប់ជើងមិនចាញ់គ្នា។
អូ...អស្ចារ្យណាស់ ! សួនច្បារក្រុមវិទ្យាល័យវេទមន្តផ្កាឈូកក្រពុំបាននិមិត្ត រៀបចំទោងយោល និងឧបករណ៍រំអិលថែមទៀតផង សួនច្បាររបស់ពួកគេមើលទៅមានឧបករណ៍កំសាន្ត ជាច្រើន សប្បាយៗជាទីរំសាយអារម្មណ៍...


ក្រឡេកមកសួនច្បារកុលាប របស់ក្រុមវិទ្យាល័យវេទមន្ត ដំឡូងខៀវវិញ យើងឃើញមាន រូបចម្លាក់សត្វជាច្រើនផងដែរ
ខណៈនេះពេលវេលាកាន់តែ ខិតចូលមកដល់ម៉ោងបញ្ចប់នៃ ការប្រកួតទៅហើយនៅសល់តែ ប្រាំនាទីទៀតប៉ុណ្ណោះ
ពួកយើងនឹងចាញ់ មិនខានបើសិនជា សួនច្បារពួកយើង មានតែរូបចម្លាក់ មួយមុខបែបនេះ
នៅសល់តែប្រាំនាទីទៀត ទេ តើកូនៗមានគំនិត ច្នៃប្រឌិតអ្វីបន្ថែមទេ?
ការប្រកួតមួយនេះ សំខាន់ណាស់ សម្រាប់វិទ្យាល័យ ពួកយើងខំប្រឹងឡើង
មិនគួរឱ្យជឿទេ ក្រុមវិទ្យាល័យវេទមន្តផ្កាឈូក ក្រពុំបាននិមិត្តអាងទឹកផ្កា កុលាបមួយដ៏ធំ
តើសួនច្បារក្រុមវិទ្យាល័យវេទមន្ត ដំឡូងខៀវមានអ្វីប្រកួតប្រជែង ជាមួយអាងទឹកផ្កាកុលាបរបស់ដៃគូ ប្រកួតទៅ រង់ចាំមើលទាំងអស់គ្នា
ក្រោយឮការអត្ថាធិប្បាយទាក់ទងនឹងអាងទឹកផ្កាកុលាបដ៏ធំរបស់ក្រុមវិទ្យាល័យវេទមន្តផ្កាឈូកក្រពុំ សិស្សដែលជាក្រុមតំណាងវិទ្យាល័យវេទមន្តដំឡូងខៀវហាក់មានការបាក់ទឹកចិត្ត ហើយក៏មានទឹកមុខស្រពាប់ស្រពោន។



នៅសល់តែបីនាទីទៀតទេ តើពួកយើងមានអ្វីអាចប្រកួតប្រជែងជាមួយពួកគេទៀតទៅ?
ពួកយើងប្រហែលជាចាញ់ហើយ...
ប៉ាវ១ សម្លឹងមើលមិត្តរួមក្រុម និងអ្នកគ្រូរបស់ពួកគេក្រៀមក្រំ អស់សង្ឃឹមត្រៀមទទួលភាពបរាជ័យ មើលទៅសិស្សដែលជាអ្នកគាំទ្រវិញក៏ឃើញថាស្ងាត់ជ្រងំមិនមានទឹកមាត់ដើម្បីស្រែកគាំទ្រទៀតនោះទេ។
....
តើខ្ញុំគួរតែសាកគំនិតរបស់ខ្ញុំទេ?
ការប្រកួតនេះសំខាន់ណាស់សម្រាប់វិទ្យាល័យពួកយើង ខ្ញុំមិនចង់ឃើញពួកយើងត្រូវចាញ់បែបនេះនោះទេ ខ្ញុំគិតថាខ្ញុំអាចបង្កើតភាពច្នៃប្រឌិតមួយប្រសើរជាងនេះសម្រាប់សួនច្បារកុលាបក្រុមពួកយើង ប៉ុន្តែពួកគេនឹងស្អប់ខ្ញុំមិនខាន បើពួកគេបានឃើញពណ៌រាងកាយដែលចម្រុះខុសគេបញ្ជាក់ពីភេទមិនច្បាស់លាស់របស់ខ្ញុំ។ តើខ្ញុំគួរសម្រេចចិត្តបែបណា?
00:02:00
ខ្ញុំមានគំនិតមួយ តើខ្ញុំអាចសាកល្បងបានទេ?
ប៉ាវ១ឈរសញ្ជឹងគិតខណៈម៉ោងថយមកសល់ត្រឹមតែពីរនាទីទៀតប៉ុណ្ណោះ។
ប៉ាវ១ និយាយឡើងតិចៗទាំងភ័យ


អ្នកគ្រូ ដែលមុននេះបាញ់ទឹកភ្នែកដូចជា
ទឹកជ្រោះឆ្លើយតបលឿនដូចព្យុះទៅកាន់ប៉ាវៗ។
ប្រាកដជាបាន
ឆាប់សាកទៅ
កូនអាចធ្វើបានប៉ាវៗ
ពួកយើងឱ្យកម្លាំងចិត្ត
កូន
ប៉ាវៗងាកទៅកាន់មិត្តរួម
ក្រុមឃើញស្នាមញញឹមផ្តល់
កម្លាំងចិត្តមកកាន់គេ។
ខណៈពេលវេលាមួយ
នាទីចុងក្រោយឈាន
ចូលមកដល់ ប៉ាវៗបិទ
ភ្នែកស្រូបដង្ហើមចូលពោះ
បន្តិចក្រោយមកខ្លួនប្រាណរបស់គេក៏ហោះអណ្តែតឡើង
ទៅលើខ្យល់អាកាស
ប៉ាវៗបញ្ចេញវេទមន្តចម្រុះពណ៌របស់គេមកមូលដូចជាដុំបាល់មួយនៅក្នុងដៃ
ខ្លួនប្រាណគេពេលនេះត្រូវបានហុំព័ទ្ធដោយវេទមន្តរបស់គេបន្តិចម្តងៗ រហូត
ជិតរាងកាយ រួមហើយក៏...


វេទមន្តចម្រុះពណ៌របស់ប៉ាវៗផ្ទុះសាយភាយពាសពេញសួនច្បារផ្កាកុលាបសរបស់ពួកគេហើយក៏បង្កើតបានជាសួនច្បារចម្រុះពណ៌មួយដែលមានសត្វអំពិលអំពែកមេអំបៅ ព្រមទាំងមានឥន្ទធនូទៀតផង។
សិស្សគ្រប់គ្នាមើលដោយមិនហ៊ានព្រិចភ្នែក។


ក្រោយនិមិត្តសួនចម្រុះពណ៌របស់គេរួចរាល់ ខ្លួនប្រាណប៉ាវៗធ្លាក់ចុះមកដីវិញសន្សឹមៗ
ពេលនេះខ្លួនប្រាណរបស់ប៉ាវៗ គឺប្រែពណ៌ចម្រុះដែលជាពណ៌រាងកាយពិតរបស់គេ។
ភ្នែកទាំងអស់សម្លឹងមកកាន់ប៉ាវៗជាមួយទឹកមុខភ្ញាក់ផ្អើល មិនទាន់មាននរណា
និយាយអ្វីផង ដោយហេតុអាថ៌កំបាំងដែលគេខំប្រឹងលាក់បំផុតបានបែកធ្លាយអស់ទៅ
ប៉ាវៗរត់ចេញពីវេទិកាប្រកួតដោយក្តីខ្មាស់អៀន។
សំឡេងហ៊ោបន្លឺឡើងកងរំពងសិស្សៗនាំគ្នា
ឱបគ្នាយំត្រេកអរ។
មិត្តរួមក្រុម មានបំណងបញ្ឈប់ប៉ាវៗ
តែភ្លាមៗ លោកនាយកក្រសួងអប់រំក៏
លើកទង់ជ័យ ជ័យលាភីមកកាន់ក្រុម
របស់វិទ្យាល័យវេទមន្តដំឡូងខៀវ។
#1
#1
សកម្មភាពទាំងអស់ត្រូវបាន
ជាប់ក្នុងការផ្សាយបន្តផ្ទាល់
របស់ប៉ុស្តិ៍ទូរទស្សន៍។


នៅព្រៃតាមផ្លូវមកផ្ទះរបស់ប៉ាវៗ
ទឹកភ្នែកហូរដូចជាទឹកដែលបាក់ទំនប់ដាបពេញផ្ទៃមុខ។ ប៉ាវៗពេលនេះហាក់កំពុងបាក់ទឹកចិត្តអស់សង្ឃឹមជាខ្លាំង។
ម៉ាក់ និងប៉ារបស់ប៉ាវៗព្យាយាមតាមរកកូនក្រោយឃើញហេតុកាណ៍ដែលបានផ្សាយបន្តផ្ទាល់តាមប៉ុស្តិ៍ទូរទស្សន៍រួចមក។
ប៉ាវៗ នៅទីនោះ!
ប៉ា និងម៉ាក់នៅជាមួយកូនចាំការពារកូនណា
មិនអីទេណាកូន ឈប់យំទៅ


ប៉ាម៉ាក់ គ្រប់គ្នានៅវិទ្យាល័យឃើញពណ៌រាងកាយពិតរបស់ខ្ញុំអស់ហើយ ពួកគេប្រាកដជា លែងរាប់អានខ្ញុំទៀតហើយ ពីពេលនេះទៅ ដោយសារខ្ញុំមានពណ៌រាងកាយដែលគ្មានភេទច្បាស់លាស់ ខ្ញុំមិនគួរណាចូលរួមសោះ
ទោះជាយ៉ាងណាប៉ា និងម៉ាក់មើលឃើញទេពកោសល្យរបស់កូន ហើយរង់ចាំផ្តល់ការគាំទ្រជានិច្ច
កុំគិតបែបនេះអីកូនធ្វើបានល្អណាស់ ថ្ងៃនេះប៉ា និងម៉ាក់ឃើញកូនតាមទូរទស្សន៍ កូនរបស់ប៉ាម៉ាក់ពិតជាឡូយ ហើយមានទេពកោសល្យ
មានទេពកោសល្យមានប្រយោជន៍អីទៅ ចុងបញ្ចប់ទេពកោសល្យរបស់ខ្ញុំនៅតែត្រូវគេមើលរំលង ដោយសារតែពណ៌រាងកាយចម្រុះដែលបញ្ជាក់ពីភេទមិនច្បាស់លាស់របស់ខ្ញុំ។ ពួកគេនឹងវិនិច្ឆ័យខ្ញុំតាមរយៈភេទមិនច្បាស់លាស់របស់ខ្ញុំដូចមិត្តថ្នាក់បឋមសិក្សារបស់ខ្ញុំដែរ។
ទោះជាយ៉ាងណាប៉ា និងម៉ាក់មើលឃើញទេពកោសល្យរបស់កូន ហើយរង់ចាំផ្តល់ការគាំទ្រជានិច្ច
តស់ ពួកយើងទៅផ្ទះវិញកូន


បន្ទប់របស់ប៉ាវៗ
ប៉ាវៗគេងលើគ្រែ ជួនកាលអង្គុយសំកុកកៀនបន្ទប់ជាមួយទឹកមុខសោកសៅ។ ប៉ាវៗ មិនបានទៅរៀន រយៈពេលបីថ្ងៃហើយ។
ខ្ញុំមិនដឹងត្រូវប្រឈមមុខជាមួយសិស្សផ្សេងទៀតនៅវិទ្យាល័យ ជាពិសេសមិត្តរួមថ្នាក់របស់ខ្ញុំយ៉ាងម៉េចទេ ក្រោយអាថ៌កំបាំងរបស់ខ្ញុំលាតត្រដាង ខ្ញុំមិនបានទៅរៀនបីថ្ងៃហើយ
តស់ ញ៉ាំបាយកូនសម្លាញ់ម៉ាក់ ថ្ងៃនេះម៉ាក់បំពងស្លាបមាន់ណា កូនចូលចិត្តវាណាស់ត្រូវអត់?
តើខ្ញុំអាចផ្លាស់ប្ដូរទៅរៀនវិទ្យាល័យផ្សេងបានទេម៉ាក់?
ម៉ាក់ និងប៉ាថា គាំទ្រកូនគ្រប់យ៉ាង នោះអី នេះជាអ្វីដែលកូនចង់បានពេលនេះ


តាមផ្លូវទៅកាន់សាលារៀន
មានពណ៌រាងកាយពណ៌ខៀវដូចទម្លាប់រាល់ដងដែលគេតែងតែលាបពណ៌រាល់ពេលចេញទៅខាងក្រៅ។ ប៉ាវៗ ដើរនៅកណ្ដាលដោយមានប៉ា និងម៉ាក់ដើរសងខាងគេ ដើរឆ្ពោះទៅកាន់វិទ្យាល័យដើម្បីធ្វើការផ្លាស់ប្ដូរវិទ្យាល័យឱ្យប៉ាវៗ។
ដើរមកដល់ក្លោងទ្វារវិទ្យាល័យក៏ងើយមើលស្លាកឈ្មោះវិទ្យាល័យបន្តិចដោយអារម្មណ៍ស្រងេះស្រងោចមិនដាច់ចិត្ត។
ខណៈនោះមិត្តរួមថ្នាក់ប្រុសម្នាក់របស់ប៉ាវៗប្រទះឃើញប៉ាវៗដែលកំពុងឈរមុខក្លោងទ្វារវិទ្យាល័យ។
ភ្លាមៗ គេដកកញ្ចែមួយពីហោប៉ៅខោ ហើយផ្លុំ។ ប៉ាវៗភ្ញាក់
ហើយក៏ថយក្រោយពួនក្រោយខ្នងម៉ាក់គេ ប៉ុន្តែក៏លួចមើលរឿងដែលកំពុងកើតឡើង




យើងឃើញសិស្សទាំងអស់ឈរចេញមកខាងក្រៅថ្នាក់ហើយស្លាកក្រណាត់ផ្ទាំងផ្សព្វផ្សាយមួយរបស់ប៉ាវៗដែលមានរូបថតរបស់ប៉ាវៗពេលប្រកួតទទួលបានជ័យជំនះជាមួយនឹងអក្សរ **« និមិត្តរូបរបស់ពួកយើង គឺម ប៉ាវប៉ាវ »**





ប៉ាម៉ាក់របស់ប៉ាវៗ រុញប៉ាវៗឱ្យមកឈរខាងមុខវិញ ហើយប៉ាវៗក៏ចាប់ផ្ដើមរលីងរលោងទឹកភ្នែក មិត្តរួមថ្នាក់របស់ប៉ាវៗមួយចំនួនរត់ចូលមកក្បែរប៉ាវៗ ហើយឱបគេ។




ពួកយើងមិនទៅរកឯងនៅផ្ទះដោយសារតែពួកយើង គិតថាឯងត្រូវការពេលខ្លះ ដើម្បីនៅម្នាក់ឯងបន្ធូរ អារម្មណ៍ពួកយើងមានរឿងមួយចង់បង្ហាញឯង
ក្រោយសិស្សប្រុសម្នាក់នេះនិយាយចប់ សិស្សមួយចំនួននាំគ្នាដកកន្សែងមកជូតខ្លួនរបស់ពួកគេ។ ប៉ាវៗក៏បើកភ្នែកធំៗចាំមើល។
ប៉ាវៗ ឯងជានិមិត្តរូបដែលជំរុញឱ្យពួកយើងហ៊ានធ្វើជាខ្លួនឯង ឯងជានិមិត្តរូបដែលបង្ហាញថាបើទោះបីពួកយើងមានរាងកាយពណ៌ចម្រុះឬពណ៌អ្វីក៏ដោយក៏ពួកយើងមានសមត្ថភាព និងអាចបង្កើតអ្វី ដែលអស្ចារ្យបានដូចគ្នា
ដោយសារគេទើបតែដឹងថា ការពិតទៅមានសិស្សជាច្រើនដែលមានពណ៌រាងកាយខុសពីពណ៌ខៀវ និងផ្កាឈូក ហើយអ្នកខ្លះទៀតគឺមានរាងកាយចម្រុះពណ៌ដូចជាគេដែរ។
តើនេះមិនមែនជាសុបិន្តទេឬ? ពេលនេះខ្លួនរបស់ខ្ញុំធូរស្រាលដូចជាទើបទម្លាក់ដុំថ្មយក្សមួយពីលើស្មាអញ្ចឹង
វាជាលើកទីមួយដែលខ្ញុំមានអារម្មណ៍ថាខ្ញុំមិនបានខុសពីអ្នកដទៃហើយគ្មានអារម្មណ៍ភ័យខ្លាចអ្វីទាំងអស់ជំនួសមកវិញដោយអារម្មណ៍សុវត្ថិភាព
ប៉ាវៗ ក្រោយឮការនិយាយរបស់ពួកគេក៏រំភើបដល់ថ្នាក់យំហើយសិស្សគ្រប់គ្នា មិនថាមានរាងកាយពណ៌ខៀវ ផ្កាឈូក ឬអ្វីក៏ដោយក៏ចូលមកឱបប៉ាវៗទាំងអស់គ្នាបង្កើតជារង្វង់មួយដ៏ធំដែលមានពណ៌ចម្រុះ?


១ ឆ្នាំកន្លងផុតទៅ
ខ្ញុំឈប់យកថ្នាំពណ៌ខៀវមកលាបរាងកាយទៀតហើយ។ ហើយតាំងពីឈប់លាបរាងកាយពណ៌ខៀវមកខ្ញុំមានអារម្មណ៍ស្រស់ស្រាយណាស់។
មិនពិបាកស្អះស្អាប់ខ្លាចមុខខ្លាចក្រោយថាវារលុបទៀតទេ
ខ្ញុំរកឃើញមិត្តមួយក្រុមធំដែលពួកគេមិនរើសអើងខ្ញុំ មិនផ្តល់សម្ពាធឱ្យខ្ញុំ មិនចំអកខ្ញុំហើយមិនចាត់ទុកខ្ញុំជាមនុស្សចម្លែកខុសពីគេដែរ។
ពួកគេផ្តល់ការលើកទឹកចិត្ត អារម្មណ៍សុវត្ថិភាពវិជ្ជមាន ដែលជំរុញឱ្យខ្ញុំធ្វើជាខ្លួនឯងដោយគ្មានភាពភ័យខ្លាច ហើយចាប់ផ្តើមក្រោកឈរប្រឈមជាមួយការរើសអើងនានា
ហើយអ្វីដែលធ្វើឱ្យខ្ញុំកាន់តែរំភើបនោះ វិទ្យាល័យខ្ញុំពេលនេះលែងមានតែពណ៌ផ្កាឈូក និងខៀវទៀតហើយ តែប្រែមកក្លាយជាវិទ្យាល័យ ដែលមានពណ៌ចម្រុះដូចជាឥន្ទធនូវិញម្តង។ ពីមួយថ្ងៃទៅមួយថ្ងៃខ្ញុំឃើញចំនួនសិស្សដែលមានពណ៌រាងកាយផ្សេងៗខុសពីពណ៌ខៀវ និងផ្កាឈូក។
មានភាពក្លាហានបង្ហាញភាពជាខ្លួនឯងឡើងមកម្តងបន្តិចៗ

ក្រោយដណ្តើមបានកញ្ចប់ប្រាក់ឧបត្ថម្ភលោកនាយកចាត់ចែងសាងសង់ជួសជុល
អគារសិក្សាជាច្រើន ហើយពេលនេះគ្រប់យ៉ាងក៏រៀបរយជាស្ថាពរ។




ប៉ាវៗ គ្រាន់តែឈានជើងចូលមកកាន់ក្លោងទ្វារវិទ្យាល័យភ្លាមក៏ចំហមាត់ WOW!
ពេលឃើញអគារសិក្សាថ្មីៗហើយ





អ្វីដែលពិសេសនោះគឺមានផ្ទាំងផ្សព្វផ្សាយមួយផ្ទាំងដែលមានដាក់រូបរបស់ប៉ាវៗ
ហើយសរសេរថា «**និមិត្តរូបរបស់ពួកយើង គឺម ប៉ាវប៉ាវ**» គឺនៅព្យួរជាប់អគារសិក្សា។

ISBN: 978-9924-9966-2-0